**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៤៤...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើក្រមព្រហ្មទណ្ឌ
- បានឃើញព្រះរាជក្រមលេខនស/រកម/០១១៥/០០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញព្រះរាជក្រមលេខនស/រកម/០១១៧/០០២ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៨ មាត្រា៤០ មាត្រា៤១ មាត្រា៤៧ មាត្រា៤៨ មាត្រា៧៥ មាត្រា៧៧ មាត្រា៨២ និងមាត្រា៩០នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក

- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២១៦អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ៤៨៨អនក្រ.បកចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់អំពីសមត្ថកិច្ច អំពើល្មើស និងចំនួនទឹកប្រាក់ដែលត្រូវពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ក្នុងគោលបំណងបង្ការទប់ស្កាត់បទល្មើសនិងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក រក្សាសណ្តាប់ធ្នាប់ចរាចរណ៍ផ្លូវគោក និងការពារអាយុជីវិតមនុស្ស សត្វ ទ្រព្យសម្បត្តិ និងបរិស្ថាន។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅៈ

-លើកកំពស់ការយល់ដឹងអំពីច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក

-បង្កើនប្រសិទ្ធភាពអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដើម្បីធ្វើឲ្យប្រសើរឡើងនូវសណ្តាប់ធ្នាប់ និងសុវត្ថិភាពចរាចរណ៍ផ្លូវគោក ។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះអំពើល្មើសនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដែលត្រូវពិន័យអន្តរការណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## សមត្ថកិច្ចនិងសិទ្ធិរបស់នគរបាលចរាចរណ៍ផ្លូវគោក ក្នុងការពិន័យអន្តរការណ៍

**មាត្រា ៤.-**

មន្ត្រីមានសមត្ថកិច្ចធ្វើការពិន័យអន្តរការណ៍រួមមានៈ

-មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោកនៃអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ និងស្នងការដ្ឋាននគរបាលរាជធានី ខេត្ត

-មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោកនាយកដ្ឋាននគរបាលចរាចរណ៍និងសណ្តាប់ធ្នាប់សាធារណៈ នៃអគ្គស្នងការ

ការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ។

**មាត្រា ៥.-**

មន្ត្រីមានសមត្ថកិច្ចធ្វើការពិន័យអន្តរការណ៍ដែលមានចែងក្នុងមាត្រា ៤ ខាងលើ មានភារកិច្ចដូចតទៅៈ

-ឃាត់ឬកោះហៅជនល្មើសមកពិន័យអន្តរការណ៍

-ទទួលប្រាក់ពិន័យអន្តរការណ៍និងចេញបង្កាន់ដៃបង់ប្រាក់ពិន័យអន្តរការណ៍ដល់ជនល្មើស

-គ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យអន្តរការណ៍

-គ្រប់គ្រងប្រាក់ចំណូលដែលបានមកពីការពិន័យអន្តរការណ៍

-ធ្វើរបាយការណ៍ស្តីពីការពិន័យអន្តរការណ៍តាមកាលកំណត់

-កសាង និងបញ្ជូនសំណុំរឿងកាន់អយ្យការអមសាលាដំបូង ក្នុងករណីជនណាមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍តាមកាលកំណត់។

## ជំពូកទី៣
## អំពើល្មើសនិងចំនួនទឹកប្រាក់ត្រូវពិន័យអន្តរការណ៍

**មាត្រា ៦.-**

ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរទោចក្រយានយន្ត ឬទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬត្រីចក្រយានយន្តចំនួនទឹកប្រាក់ ១៥ ០០០(មួយម៉ឺនប្រាំពាន់)រៀល អ្នកបើកបរយានយន្តធុនស្រាលចំនួនទឹកប្រាក់ ២៥ ០០០(ពីរម៉ឺនប្រាំពាន់)រៀល និងអ្នកបើកបរយានយន្តធុនធ្ងន់ចំនួនទឹកប្រាក់ ៥០ ០០០(ប្រាំម៉ឺន)រៀល ចំពោះអំពើល្មើសដូចខាងក្រោមៈ

ក-អ្នកបើកបរទោចក្រយានយន្តនិងអ្នករួមដំណើរព្រមទាំងកុមារដែលមានអាយុពី០៣(បី)ឆ្នាំឡើង ទៅមិនពាក់មួកសុវត្ថិភាព ឬពាក់មួកសុវត្ថិភាពមិនត្រឹមត្រូវតាមស្តង់ដាជាតិ ឬពាក់មួកសុវត្ថិភាពដោយ មិនដាក់គន្លឹះខ្សែសុវត្ថិភាព។ ការពិន័យអន្តរការណ៍ករណីល្មើសនេះត្រូវគិតតាមចំនួនអ្នកប្រព្រឹត្តល្មើសលើកលែងកុមារ ។

អ្នកបើកបរត្រីចក្រយានយន្ត ឬអ្នកបើកបរទោចក្រយានយន្តសណ្តោងរ៉ឺម៉កមិនពាក់មួកសុវត្ថិភាព ឬពាក់មួកសុវត្ថិភាពមិនត្រឹមត្រូវតាមស្តង់ដាជាតិ ឬពាក់មួកសុវត្ថិភាពដោយមិនដាក់គន្លឹះខ្សែសុវត្ថិភាព។

ខ-អ្នកបើកបរយានយន្តដែលមិនបានយកភ្ជាប់តាមខ្លួននូវឯកសារដើម រួមមាន បណ្ណបើកបរយានយន្ត វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត និងលិខិតអនុញ្ញាតធ្វើអាជីវកម្មចំពោះរថយន្តដែលប្រកបអាជីវកម្មដឹកជញ្ជូន។

គ-អ្នកបើកបររថយន្តគ្រប់ប្រភេទនិងអ្នករួមដំណើរជិះកៅអីមុខនៃរថយន្តមិនពាក់ខ្សែក្រវ៉ាត់សុវត្ថិភាព។

ឃ-អ្នកបើកបរយានយន្តឈប់ឬចតល្មើសនឹងមាត្រា២៣នៃច្បាប់ស្តីចរាចរណ៍ផ្លូវគោក។

ង-អ្នកបើកបរយានយន្តបើកបរដោយកុងទ័រល្បឿនមិនដំណើរការ។

ច-អ្នកបើកបរយានយន្តហួសល្បឿនកំណត់ចាប់ពី០១ទៅ១៩គីឡូម៉ែត្រក្នុងមួយម៉ោង។

ឆ-អ្នកបើកបរយានយន្តប្រើប្រាស់ទូរស័ព្ទគ្មានឧបករណ៍សម្លេងភ្ជាប់ទំនាក់ទំនងនៅពេលកំពុងបើកបរ។

ជ-អ្នកបើកបរយានយន្តប្រើសញ្ញាសូរស័ព្ទមិនត្រឹមត្រូវតាមបទប្បញ្ញត្តិច្បាប់។

ឈ-អ្នកបើកបរយានយន្តដឹកអ្នកដំណើរលើសចំណុះល្មើសនឹងចំណុចទី៨ មាត្រា៨ និងចំណុចទី៦ មាត្រា៥៦។

នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។ អំពើល្មើសចំណុចទី៨ មាត្រា៨ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក អាចលើកលែងបានក្នុងករណីដឹកអ្នកជម្ងឺ។

## មាត្រា ៧.-

ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរទោចក្រយានយន្ត ឬទោចក្រយានយន្តសណ្តោងរ៉ឺម៉កឬត្រីចក្រយានយន្តចំនួនទឹកប្រាក់២០ ០០០(ពីរម៉ឺន)រៀល អ្នកបើកបរយានយន្តធុនស្រាលចំនួនទឹកប្រាក់៤០ ០០០ (បួនម៉ឺន)រៀល និងអ្នកបើកបរយានយន្តធុនធ្ងន់ចំនួនទឹកប្រាក់៧៥ ០០០(ប្រាំពីរម៉ឺនប្រាំពាន់)រៀល ចំពោះអំពើល្មើសដូចខាងក្រោម៖

ក-អ្នកបើកបរទោចក្រយានយន្តអូសចន្ទល់លើផ្លូវថ្នល់ឬព្រលែងដៃចង្កូត ឬលើកជើងដាក់លើដៃចង្កូត។

ខ-អ្នកបើកបរយានយន្តបង្ហោះ រេចុះរេឡើង ឆាប ឬកៀរ ។

គ-អ្នកបើកបរយានយន្តរៀបចំដាក់តាំងភ្លើង និងភ្លើងសញ្ញានៃយានជំនិះ មិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។

ឃ-អ្នកបើកបរយានយន្តដែលម៉ាស៊ីនបញ្ចេញសម្លេងខ្លាំងឬផ្សែងច្រើនខុសពីបទដ្ឋានបច្ចេកទេស។

ង-អ្នកបើកបរយានយន្តដែលគ្មានឬមិនដំណើរការនូវផ្លិតទឹកជូតកញ្ចក់មុខ ឬកញ្ចក់មុខ ឬកញ្ចក់ក្រោយមានប្រេះស្រាំដែលលំបាកមើលផ្លូវ ឬគ្មានកញ្ចក់មើលក្រោយ។

ច-អ្នកបើកបរយានយន្តហួសល្បឿនកំណត់ចាប់ពី ២០ ទៅ ២៩គីឡូម៉ែត្រក្នុងមួយម៉ោង។

ឆ-អ្នកបើកបររថយន្តធ្វើអាជីវកម្មដឹកអ្នកដំណើរ ឬដឹកទំនិញមិនមានសញ្ញាសម្គាល់ឬប្រើសញ្ញាសម្គាល់មិនត្រឹមត្រូវ។

ជ-អ្នកបើកបររថយន្តដឹកទំនិញមានគ្រោះថ្នាក់ មិនមានសញ្ញាសម្គាល់ ឬប្រើសញ្ញាសម្គាល់មិនត្រឹមត្រូវ ។

ឈ-អ្នកបើកបរយានយន្តល្មើសនឹងបែបបទនៃការសណ្តោងយានដូចមានចែងក្នុងមាត្រា១៤ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

ញ-អ្នកបើកបរយានយន្តដែលមិនបានប្រើភ្លើងសញ្ញាអាសន្ន ឬមិនបានដាក់សញ្ញាត្រីកោណជាដំណឹងក្នុងករណីដែលយានយន្តខូចមិនអាចរំកិលចេញពីទ្រូងផ្លូវបាន ។ អ្នកបើកបរយានយន្តដែលមិនបានប្រើភ្លើងសញ្ញាអាសន្ន ឬមិនបានដាក់សញ្ញាត្រីកោណជាដំណឹងសម្រាប់ការពារគ្រោះថ្នាក់ ក្នុងករណីដែលយានយន្តខូចមិនអាចរំកិលចេញពីទ្រូងផ្លូវបាននៅកន្លែងផ្លូវកោង ឬផ្លូវបត់ ឬផ្លូវចោត ។

## មាត្រា ៨.-

ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរទោចក្រយានយន្ត ឬទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬត្រីចក្រយានយន្តចំនួនទឹកប្រាក់២៥ ០០០(ពីរម៉ឺនប្រាំពាន់)រៀល អ្នកបើកបរយានយន្តធុនស្រាលចំនួនទឹកប្រាក់ ៥០ ០០០ (ប្រាំម៉ឺន)រៀល និងអ្នកបើកបរយានយន្តធុនធ្ងន់ចំនួនទឹកប្រាក់ ១០០ ០០០(មួយសែន)រៀល ចំពោះអំពើល្មើសដូចខាងក្រោម៖

ក-អ្នកបើកបរយានយន្តបើកបរដោយពុំមានលិខិតអនុញ្ញាតធ្វើអាជីវកម្ម ឬប្រើលិខិតធ្វើអាជីវកម្មហួសសុពលភាព។

ខ-អ្នកបើកបរយានយន្តមិនគោរពតាមលក្ខខណ្ឌសុខភាពដែលតម្រូវឲ្យពាក់វ៉ែនតា។

គ-អ្នកបើកបរយានយន្តខុសទិសដែលតម្រូវឲ្យធ្វើចរាចរណ៍ ឬបើកបរជាន់គំនូសបង្កួតកណ្តាលទ្រូងផ្លូវ។

ឃ-អ្នកបើកបរយានយន្តហួសល្បឿនកំណត់ចាប់ពី ៣០ ទៅ ៣៩ គីឡូម៉ែត្រក្នុងមួយម៉ោង។

ង-អ្នកបើកបរយានយន្តល្មើសនឹងការជៀសការបត់និងការជែង។/

ច-អ្នកបើកបរយានយន្តល្មើសនឹងសិទ្ធិអាទិភាពនៅផ្លូវប្រសព្វ។

ឆ-អ្នកបើកបរយានយន្តល្មើសនឹងការប្រើប្រាស់ភ្លើងបំភ្លឺ ឬកែច្នៃភ្លើងបំភ្លឺ ឬភ្លើងសញ្ញានៃយានមិនត្រឹមត្រូវតាមស្តង់ដាបច្ចេកទេសជាតិ។

ជ-អ្នកបើកបរយានយន្តដែលមិនមាន ឬមិនដំណើរការភ្លើងបំភ្លឺ ឬភ្លើងសញ្ញានៃយាន។

ឈ-អ្នកបើកបរយានយន្តមិនគោរពភ្លើងសញ្ញាចរាចរណ៍ពណ៌ក្រហម ឬក្រហមភ្លឺបភ្លែតៗ។

ញ-អ្នកបើកបរយានយន្តមិនគោរពផ្លាកសញ្ញាហាមឃាត់ឬផ្លាកសញ្ញាបញ្ជា ឬផ្លាកសញ្ញាសិទ្ធិអាទិភាព ឬគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់។

ដ-អ្នកបើកបរយានយន្តប្រព្រឹត្តមិនរាងចាលនូវអំពើល្មើសស្តីពីការឈប់ ឬចត។

ឋ-អ្នកបើកបរយានយន្តប្រើប្រាស់សំបកកង់សឹកលើសកម្រិតកំណត់ ឬរហែក ឬប្រេះ ឬប៉ោង។

ឌ-អ្នកបើកបរយានយន្តមិនគោរពសញ្ញាបញ្ជាចរាចរណ៍របស់ភ្នាក់ងារនគរបាលចរាចរណ៍។

ឍ-អ្នកបើកបរយានយន្តផ្ទុកទំនិញល្មើសនឹងចំណុចទី១ ចំណុចទី២ ចំណុចទី៣ ចំណុចទី៤ ចំណុចទី៥ មាត្រា៥៦ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

ណ-អ្នកបើកបររថយន្តធុនធ្ងន់ដែលគ្មានរនាំងសុវត្ថិភាព ឬមានរនាំងសុវត្ថិភាពមិនត្រឹមត្រូវតាមបណ្តោយតួរថយន្តខាងក្រោម ឬគ្មានគន្លឹះសុវត្ថិភាពសម្រាប់ភ្ជាប់កុងតឺន័រ ឬគន្លឹះសុវត្ថិភាពសម្រាប់ភ្ជាប់កុងតឺន័រមិនដំណើរការ ។

## មាត្រា ៩.-

ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរទោចក្រយានយន្ត ឬទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬត្រីចក្រយានយន្តចំនួនទឹកប្រាក់៣០ ០០០(បីម៉ឺន)រៀល អ្នកបើកបរយានយន្តធុនស្រាលចំនួនទឹកប្រាក់ ៦០ ០០០ (ប្រាំមួយម៉ឺន)រៀល និងអ្នកបើកបរយានយន្តធុនធ្ងន់ចំនួនទឹកប្រាក់ ១២៥ ០០០(មួយសែនពីរម៉ឺនប្រាំពាន់)រៀល ចំពោះអំពើល្មើសដូចខាងក្រោម៖

ក-អ្នកបើកបរទោចក្រយានយន្តមានទំហំស៊ីឡាំងលើសពី ១២៥ (មួយរយម្ភៃប្រាំ) សង្ទីម៉ែត្រគូប ឬមានថាមពលអគ្គិសនីលើសពី១១ (ដប់មួយ) គីឡូវ៉ាត់ ឬទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬត្រីចក្រយានយន្តដោយគ្មានបណ្ណបើកបរ ឬក្នុងរយៈពេលដែលបណ្ណបើកបរត្រូវបានដកហូតព្យួរទុក ឬទុកជាមោឃៈ។

ខ-អ្នកបើកបរទោចក្រយានយន្ត ឬទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬត្រីចក្រយានយន្តដោយគ្មានបណ្ណសម្គាល់ និង/ឬផ្លាកលេខ។

គ-ម្ចាស់យានយន្តមិនបានផ្ទេរកម្មសិទ្ធិយានយន្តលើសរយៈពេលកំណត់ដែលមានចែងក្នុងប្រកាសអន្តរក្រសួងរវាងក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ឃ-អ្នកបើកបរយានយន្តបើកបរដោយពុំមានវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយាន ឬប្រើវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសហួសសុពលភាព។

ង-អ្នកបើកបរយានយន្តគ្រប់ប្រភេទដែលប្តូរពណ៌ដោយគ្មានការអនុញ្ញាត ឬបិទពណ៌មិនត្រឹមត្រូវតាមបណ្ណសម្គាល់យានយន្ត។

ច-អ្នកបើកបរយានយន្តប្រើប្រាស់បណ្ណបើកបរមិនត្រឹមត្រូវតាមប្រភេទយាន។

ឆ-អ្នកបើកបរយានយន្តប្រើបណ្ណបើកបរហួសសុពលភាព។

ជ-អ្នកបើកបរយានដែលមានកង់ច្រវ៉ាក់ដែកផ្ទាល់នៅលើទ្រូងផ្លូវថ្នល់ក្រាលកៅស៊ូ។

ឈ-អ្នកបើកបរយានយន្តហួសល្បឿនកំណត់ចាប់ពី៤០(សែសិប)គីឡូម៉ែត្រក្នុងមួយម៉ោងឡើងទៅ។

៣-អ្នកបើកបរយានយន្តប្រើប្រាស់ផ្លាកលេខសម្គាល់យានដែលរចនាខុសពីលក្ខណៈដើម ឬលុបលេខ ឬបាក់ផ្លាកបាត់លេខ ឬដាក់សម្ភារៈ ឬវត្ថុផ្សេងៗ បាំងផ្លាកលេខ ។

ង-អ្នកបើកបរយានយន្តមានអត្រាជាតិអាកុលចាប់ពី០,២៥ ទៅ ០,៣៩មីលីក្រាម ក្នុងមួយលីត្រខ្យល់ ឬចាប់ពី០,៥ ទៅ ០,៧៩ក្រាម ក្នុងមួយលីត្រឈាម។

ឋ-អ្នកបើកបររថយន្តឲ្យមនុស្សជិះលើយានដែលកំពុងសណ្តោង ក្រៅពីអ្នកបើកបរ។

ឱ-អ្នកបើកបរយានយន្តកែច្នៃយានយន្តខុសបទដ្ឋានបច្ចេកទេស។

ឈ-អ្នកបើកបរយានយន្តប្រណាំងយានដោយគ្មានការអនុញ្ញាតលើផ្លូវសម្រាប់ធ្វើចរាចរណ៍ជាសាធារណៈ។

## មាត្រា ១០.-

ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរយានយន្តដោយគ្មានបណ្ណបើកបរ ឬក្នុងរយៈពេលដែលបណ្ណបើកបរត្រូវបានដកហូតព្យួរទុក ឬទុកជាមោឃៈ ដូចតទៅ៖

-ចំនួនទឹកប្រាក់ ៤០០ ០០០(បួនសែន)រៀល សម្រាប់យានយន្តធុនស្រាល

-ចំនួនទឹកប្រាក់ ៨០០ ០០០(ប្រាំបីសែន)រៀល សម្រាប់យានយន្តធុនធ្ងន់ ។

ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តបទល្មើសនេះទៀត ក្នុងកំឡុងពេល ៦ (ប្រាំមួយ)ខែ ចាប់គិតពីការពិន័យអន្តរការណ៍លើកមុន ត្រូវកសាងសំណុំរឿងបញ្ជូនទៅកាន់អយ្យការអមសាលាដំបូង ។

ចំពោះអ្នកបើកបរទោចក្រយានយន្ត ឬទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬត្រីចក្រយានយន្ត ត្រូវអនុវត្តតាមប្បញ្ញត្តិនៃមាត្រា៩ ខាងលើនេះ។

## មាត្រា ១១.-

ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរយានយន្តដែលបើកបរស្ថិតក្នុងភាពស្រវឹងមានអត្រាជាតិអាល់កុលចាប់ពី០,៤០ (សូនក្បៀសសែសិប) មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី០,៨០(សូនក្បៀសប៉ែតសិប) ក្នុងមួយលីត្រឈាមឡើងទៅដូចតទៅ៖

-ចំនួនទឹកប្រាក់ ២០០ ០០០(ពីរសែន)រៀល សម្រាប់ ទោចក្រយានយន្ត ឬទោចក្រយានយន្តសណ្តោងរ៉ឺម៉កឬត្រីចក្រយានយន្ត

-ចំនួនទឹកប្រាក់ ៤០០ ០០០(បួនសែន)រៀល សម្រាប់យានយន្តធុនស្រាល

-ចំនួនទឹកប្រាក់ ៨០០ ០០០(ប្រាំបីសែន)រៀល សម្រាប់យានយន្តធុនធ្ងន់ ។

អ្នកបើកបរយានយន្តដែលបើកបរស្ថិតក្នុងភាពស្រវឹងមានអត្រាជាតិអាល់កុលដូចបានចែងក្នុងមាត្រានេះត្រូវបញ្ឈប់មិនអោយបើកបរយានយន្តរហូតដល់អត្រាជាតិអាល់កុលចុះក្រោម០,២៥(សូន្យក្បៀសម្ភៃប្រាំ)មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬក្រោម០,៥ (សូន្យក្បៀសប្រាំ)ក្រាម ក្នុងមួយលីត្រឈាម ។

ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តបទល្មើសនេះទៀត ក្នុងកំលុងពេល ៦ (ប្រាំមួយ)ខែ ចាប់គិតពីការពិន័យអន្តរការណ៍លើកមុន ត្រូវកសាងសំណុំរឿងបញ្ជូនទៅកាន់អយ្យការអមសាលាដំបូង ។

## មាត្រា ១២.-

ត្រូវពិន័យអន្តរការណ៍ចំពោះជនណាប្រើប្រាស់យានយន្ត ដោយគ្មានបណ្ណសម្គាល់យានយន្ត ឬគ្មានផ្លាកលេខដូចតទៅ៖

-ចំនួនទឹកប្រាក់ ៤០០ ០០០(បួនសែន)រៀល សម្រាប់យានយន្តធុនស្រាល

-ចំនួនទឹកប្រាក់ ៨០០ ០០០(ប្រាំបីសែន)រៀល សម្រាប់យានយន្តធុនធ្ងន់ ។

ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តបទល្មើសនេះទៀត ក្នុងកំឡុងពេល ៦ (ប្រាំមួយ)ខែ ចាប់គិតពីការពិន័យអន្តរការណ៍លើកមុន ត្រូវកសាងសំណុំរឿងបញ្ជូនទៅកាន់អយ្យការអមសាលាដំបូង ។

ចំពោះទោចក្រយានយន្ត ឬទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬត្រីចក្រយានយន្ត ត្រូវអនុវត្តតាមប្បញ្ញត្តិនៃមាត្រា៩ ខាងលើនេះ ។

## មាត្រា ១៣._

ឪពុកម្តាយ ឬអាណាព្យាបាល ត្រូវបង់ប្រាក់ពិន័យអន្តរការណ៍ចំពោះអំពើរបស់អនីតិជនមានអាយុក្រោម ១៥ឆ្នាំ ដែលបានប្រព្រឹត្តល្មើសនឹងអនុក្រឹត្យនេះ ។

## មាត្រា ១៤._

ការពិន័យអន្តរការណ៍ចំពោះអំពើល្មើសដែលមានមានចែងក្នុងមាត្រា៦ មាត្រា៧ មាត្រា៨ មាត្រា៩ មាត្រា ១០ មាត្រា១១ និងមាត្រា១២ខាងលើ ត្រូវអនុវត្តចំពោះអ្នកបើកបរយានយន្ត លើកលែងចំណុច " គ " នៃមាត្រា៩ និងមាត្រា១៣ នៃអនុក្រឹត្យនេះ ។

ក្នុងករណីដែលជនល្មើសបានប្រព្រឹត្តល្មើសនឹងមាត្រា៦ មាត្រា៧ មាត្រា៨ មាត្រា៩ មាត្រា ១០ មាត្រា ១១ មាត្រា១២ និងមាត្រា១៣ មិនបានបង់ប្រាក់ពិន័យអន្តរការណ៍ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃដែលបានទទួលបង្កាន់ដៃពិន័យអន្តរការណ៍ ចំនួនទឹកប្រាក់ពិន័យនេះត្រូវតម្លើងជាពីរដង បើលើសពី៦០(ហុកសិប)ថ្ងៃ ចំនួនទឹកប្រាក់ពិន័យនេះត្រូវតម្លើងជាបីដង ។ បើផុតរយៈពេល៩០(កៅសិប)ថ្ងៃ មន្ត្រីមានសមត្ថកិច្ចត្រូវរៀបចំសំណុំរឿងបញ្ជូនទៅអយ្យការអមតុលាការសាលាដំបូងតាមនីតិវិធី ។

ទម្រង់បែបបទនៃបង្កាន់ដៃពិន័យ និងការគ្រប់គ្រងប្រាក់ចំណូលដែលបានមកពីការពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ។

## មាត្រា ១៥._

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់មន្ត្រីមានសមត្ថកិច្ចដូចមានចែងក្នុងមាត្រា៤ នៃអនុក្រឹត្យនេះ មានសិទ្ធិប្តឹងតវ៉ារយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ គិតពីថ្ងៃទទួលបង្កាន់ដៃអន្តរការណ៍ ទៅប្រធានអង្គភាពដែលគ្រប់គ្រងលើមន្ត្រីអនុវត្តផ្ទាល់គឺ៖

- នៅថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវប្តឹងតវ៉ាទៅអធិការនគរបាលក្រុង ស្រុក ខណ្ឌ
- នៅថ្នាក់រាជធានី ខេត្ត ត្រូវប្តឹងតវ៉ាទៅស្នងការនគរបាលរាជធានី ខេត្ត
- នៅថ្នាក់ក្រសួង ត្រូវប្តឹងតវ៉ាទៅប្រធាននាយកដ្ឋាននគរបាលចរាចរណ៍និងសណ្តាប់ធ្នាប់សាធារណៈ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ។

ប្រធានអង្គភាពត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃយ៉ាងយូរ គិតពីថ្ងៃទទួលបណ្តឹង។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ប្រធានអង្គភាពខាងលើ មានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធី។

# ជំពូកទី៤
# អវសានប្បញ្ញត្តិ

**មាត្រា ១៦.-**

អនុក្រឹត្យលេខ៨៥ អនក្រ.បក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ហើយត្រូវជំនួសដោយអនុក្រឹត្យនេះ។

**មាត្រា ១៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការដ្ឋានគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
សូមហត្ថលេខា។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោ
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីប្រចាំការ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ដូចមាត្រា១៧
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ